**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខ:.....៣១៣/២០..ក.ប/អ.ក/អ.ធ.ក/ព.ក

**ជម្រាបមក**

**លោក ម្ចាស់ ឬនាយកក្រុមហ៊ុន ម៉ាក ប៊ែក (ខេមបូឌា) ខូ អិលធីឌី (វិស័យកាត់ដេរ)**

អាសយដ្ឋាន៖ សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

**យោង** ៖ លិខិតលេខ ២០០៧០២៣៣៧០ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ម៉ាក ប៊ែក (ខេមបូឌា) ខូ អិលធីឌី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក ម្ចាស់ ឬនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣៥៨នាក់ (ស្រី ២៧៦នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ៣៧៤នាក់ (ស្រី ២៨៦នាក់) រយៈពេលចំនួន ៥៧ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ ក្នុងនោះ៖

- កម្មករនិយោជិតចំនួន ៣៥៥នាក់ (ស្រី ២៧៣នាក់) ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ ដុល្លារអាមេរិកក្នុងមួយខែ
- កម្មករនិយោជិតចំនួន ៣នាក់ (ស្រី ៣នាក់) មិនទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល។

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់ កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោក ម្ចាស់ ឬនាយក** ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី **លោក ម្ចាស់ ឬនាយក** ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ)មុនថ្ងៃចូលធ្វើការ ហើយ **លោក** ត្រូវទទួលខុសត្រូវបង់ជួសកម្មករនិយោជិត ទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរកម្មករនិយោជិតដែលបានចូលធ្វើការមុនកំណត់ទាំងនេះ។ ក្នុងករណីចាំបាច់ **លោក** អាចស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារមុនកាលកំណត់បានចំនួន ១លើក។ ករណីលើសពី ១លើក **លោក** ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករនិយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ។

អាស្រ័យដូចនេះ សូម **លោក ម្ចាស់ ឬនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោក ម្ចាស់ ឬនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។ Sal

ថ្ងៃ ចន្ទ ១រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០

**ត.ប. រដ្ឋមន្ត្រី**

**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ** ph.

**អ៊ឹក_ចាន់ធូ**

ចម្លងជូន:

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលរាជធានីភ្នំពេញ